# សិលាចារឹកអ្នកតាតាំងរាយ K.៦២៨

## ១- ព័ត៌មានទូទៅ

អ្នកតាតាំងរាយ ជាទីទួលដែលមានសំណេះសំណល់សម្ភារៈសំណង់ប្រាសាទសម័យបុរាណ ស្ថិតនៅក្នុងភូមិសណ្ដែក ឃុំសណ្ដែក ស្រុកបាធាយ ខេត្តកំពង់ចាម។ ទីតាំងនេះ មានក្ដីបាក់បែកមួយរាងបួនជ្រុងស្មើ ធ្វើពីឥដ្ឋ និងមានឃើញគ្រឹះធ្វើពីថ្មបាយក្រៀម ព្រមទាំងស្នាកស្នាមមណ្ឌប(?)លយមកខាងមុខផង។ ក្ដីនេះ មានកសិន្ធុព័ទ្ធជុំវិញ មានច្រកចូលពីខាងកើតតាមស៊ុមទ្វារធ្វើពីថ្មភក់[១]។

នៅទីនេះធ្លាប់រកឃើញផ្ដែរប្រាសាទ រចនាបថបាពួន មានចម្លាក់ព្រះនារាយណ៍ផ្ទំលើនាគអនន្ត ដែលអំឡុងឆ្នាំ២០០៧ ក្រុមការងារ CISARK ប្រទះឃើញនៅសល់តែពាក្យកណ្ដាលផ្នែកខាងស្ដាំប៉ុណ្ណោះ។ ស្ថាននាម «តាំងរាយ» នេះ បង្ហាញពីទំនាក់ទំនងរវាងឈ្មោះទីតាំងជាមួយនិងចម្លាក់ព្រះនារាយណ៍ផ្ទំនៅលើផ្ដែរនេះ។ ដ្បិតថាពាក្យ «តាំង» ច្រើនតែជាពាក្យហៅសំដៅដល់ទីទួល ដែលមានស្នាកស្នាមប្រាសាទបុរាណ នៅតាមតំបន់មួយចំនួនក្នុងប្រទេសកម្ពុជា។ ចំណែកឯពាក្យ «រាយ» នេះ ទំនងជាពាក្យកាត់ខ្លីចេញពីពាក្យ «នារាយណ៍» ដែលមានប្រភពមកសំស្ក្រឹត។ នៅទីនោះក៏មានបល្ល័ង្កថ្មភក់សម័យអង្គរស.វ.ទី១១ មួយ ដែលតាមលក្ខណៈរន្ធសម្រាប់បញ្ចុះ គឺប្រហែលជាជើងទម្រសម្រាប់តម្កល់ទេវរូប។ នៅឆ្នាំ១៩២៩ គេក៏បានរកឃើញសិលាចារឹកសម័យមុនអង្គរមួយផ្ទាំង ចារជាភាសាខ្មែរបុរាណ ចំនួន១៨បន្ទាត់។ ដូច្នេះទីតាំងនេះ ទំនងជាកសាងឡើងតាំងពីសម័យមុនអង្គរ និងជួសជុលឬសាងបន្ថែមនៅក្នុងស.វ.ទី១១ នាសម័យបាពួន។ បើពុំដូច្នោះ សិលាចារឹកសម័យមុនអង្គរមួយផ្ទាំងនេះ អាចរកឃើញនៅតំបន់ក្បែរនោះ និងយកមករក្សាទុកនៅទីតាំងនេះ។ បច្ចុប្បន្ន ផ្ទាំងសិលាចារឹកនេះ និងកំណាត់ផ្ដែរ ពុំស្ថិតនៅទីតាំងអ្នកតាតាំងរាយនេះទេ។

---

[១] https://cisark.mcfa.gov.kh/core/showsite.php?id=4648

អត្ថបទដោយៈ ហ៊ុន ឈុនតេង

សិលាចារឹកនេះ មានចុះកាលបរិច្ឆេ ប៉ុន្តែកាលបរិច្ឆេទនេះបានដាច់អស់ច្រើន អាចឱ្យដល់ត្រឹមតែស្ថិតនៅចន្លោះមហាសករាជឆ្នាំ៥០០ ឬចន្លោះរវាងចុងស.វ.ទី៦ដល់ពាក់កណ្តាលស.វ.ទី៧ ដែលសមស្របតាមលក្ខណៈបុរាណលេខន៍ផងដែរ។ ចំពោះអត្ថន័យសង្ខេបនៃសិលាចារឹកនេះ គឺជាបញ្ជីតង្វាយអ្នកបម្រើប្រុសស្រី គោក្របី និងស្រែចម្ការចំពោះប្រាសាទព្រះគម្តែងអញស្រីអរិមុក្តេសូរ ដែលជាប្រាសាទព្រះឥសូរ។ បើយោងតាមចម្លាក់ផ្តែរព្រះវិស្ណុធំ ប្រាសាទនេះទំនងជាកែប្រែពីប្រាសាទព្រះឥសូរទៅជាប្រាសាទរបស់ព្រះនារាយណ៍វិញ នៅស.វ.ទី១១។

បើយោងតាមប្រព័ន្ធមណ្ឌល ការបង្ហាញពាក្យ «កុរាកិក្មោញស្រុកិក្រៅ» សំដៅដល់កុរាកដែលជាមេស្រុកក្រៅ ទំនងជាបង្ហាញថាតំបន់រកឃើញសិលាចារឹកនិងតំបន់ជុំវិញនេះ គឺជាខេត្តក្រៅ មានមេកើយគ្រប់គ្រង និងមិនស្ថិតនៅដែនខាងក្នុង ដែលគ្រប់គ្រងដោយអំណាចកណ្តាលដែលវ្យាធបុរ ឬឦសានបុរ ផ្ទាល់។

## ២- អត្ថបទដើមជាអក្សរខ្មែរទំនើប

១- [---]ញ្ចគតគកបរិគ្រហ--------វ្ទ

២- [---]ហស្បតីទិនវារកុរាកិក្មោញិស្រុកិក្រៅ

៣- [---]កម្រតាងអញ្ជគ្រីអរិមុក្តកេគ្វរយោទ

៤- [---]វាភានុទត៑១វាកុមារទេវ១វាបូណ្ណ៌មី១វាកញ្ជា១

៥- [---]១វាជម្នាគ្រយ១វាត្ងៃគុណិតព្រៅ១វាកំវត៑១

៦- [---]១វាកទ១វាគិរទោស១វាក្មាស្ងេល៑១វាត្ងៃត៑១វា

៧- [---]វា(ចល)១វាកដិង៑១វាធនាគ១វាក្រាំ១វាកញ្ចែស៑១

៨- [---]១អ្នកិកន្តេកុក្ជន៑១កោនិកុអន្តេង៑១កុជារ១កុឈេ១

៩- [---]១កុប្រើំ១កោនិកុវាអបិក៑១វាផោង៑១កុបិត១កុកន្តេក៑១

១០- [---]១កោនិកុឯការលី១កុត្រេន៑១កោនិកុតុក្តរ៑១

១១- [---]កោនិកុកន្ទុរ៑១វាកន្សេង៑១កុត្ងាល៑១កោនិកុសានមតី១

អត្ថបទដោយៈ ហ៊ុន ឈុនតេង

១២- [---]កោនិកុត្តី១កុតាង៑ប្អូនិ១កោនិកុសុខាបតី១កុត្យសិ១

១៣- [---]ទ្រោសិ១កុកនិអ១កុមេយិ១កុឧបល១វាត្នះ១

១៤- [---]កុវាអលង៑១កុត្មោញិ១វាប្រាន១កុកជកិ១កោនិ

១៥- [---]ទ្រអញិ១កុតឯតិ១កោនិកុត្តបិ១កុអទ្រោកិ១

១៦- [---]ង៑១កុសភា១កោនិកុប្រីតិ១វាអគតិ១បិណ្ឌាសវា

១៧- [---]៣ស្រេសវ២០ត្នរិក្របិទំរិង៑ស្រេវៃសល៧

១៨- [---]ស្រេត្កោលិវសេនិ៧សវេ

## ៣- អត្ថបទប្រែសម្រួល

មហាសករាជឆ្នាំ៥-- [---] ថ្ងៃព្រហស្បត៏ កុរាកក្មោញស្រុកក្រៅ(ថ្វាយអ្នកបម្រើ) ចំពោះព្រះគម្តែងអញស្រីអវិមុក្តកេសូវ។ អ្នកបម្រើប្រុសៈ វាភានុទត១ វាកុមារទេវ១ វាបូណ្ណ៍មី១ វាកញ្ជា១ វាធម្មាស្រ័យ១ វាត្វេគុណិតព្រៅ១ វាកំវត១ វាភទ១ វាគិវទាស១ វាក្មាស្វេល១ វាត្វេត១ វាចល១ វាកជិង១ វាធនាគ១ វាក្រោម១ វាកញ្ចេស១។ អ្នកបម្រើស្រីៈ កុក្ទូន១ កូនគឺកុអន្តេង១ កុជារ១ កុឈេ១ កុប្រេម១ កូនគឺកុវាអបិក១ វាង៉ោង១ កុបិត១ កុកន្តេក១ [---]និង៑កូនគឺកុឯការលី១ កុត្រេន១ និង៑កូនគឺកុតុក្តរ១ [---]និង៑កូនគឺកុកន្ទុរ១ វាកន្សេង១ កុត្វាល១ និង៑កូនគឺកុសានមតី១ [---]និង៑កូនគឺកុត្តី១ កុតាង៑ប្អូន១ និង៑កូនគឺកុសុខាបតី១ កុត្យស១ [---]ទ្រោស១ កុកន្អ១ កុមេយ១ កុឧបល១ វាត្នះ១ កុវាអលង៑១ កុត្មោញ១ វាប្រាន១ កុកជក១ និង៑កូនគឺ [---]ទ្រអញ១ កុត្ឯត១ និង៑កូនគឺកុត្តប១ កុអទ្រោក១ [---]ង៑១ កុសភា១ និង៑កូនគឺកុប្រីតិ១ វាអគតិ១។ សរុបទាំងក្មេងចាស់ប្រុសស្រី---។ ---ស្រែ២០សន្ទ្រែគោ ក្របី ច្បារដំណាំទ្រើង ស្រែវៃសល៧ [---]ស្រែត្កោលវសេន ៧ សន្ទ្រែ។

## បញ្ជីឯកសារ


Cœdès, George. (1954). Inscriptions du Vat Práḥ Ĕinkosĕi. In *Inscription du Cambodge* (Vol. VI, pp. 16-17). Paris: Editions de Boccard.

https://cisark.mcfa.gov.kh/core/showsite.php?id=4648


អត្ថបទដោយៈ ហ៊ុន ឈុនតេង

# បញ្ជីរូបភាព



ទួលអ្នកតាតាំងពាយ (រូបថត៖ CISARK)



បំណែកផ្តែរនៅទួលអ្នកតាតាំងពាយ (រូបថត៖ CISARK)

អត្ថបទដោយ៖ ហ៊ិន ឈុនតេង



ផ្តែរនៅទួលអ្នកតាតាំងពាយកាលនៅពេញលេញ (រូបថត៖ CISARK)



ជើងទម្រនៅទួលអ្នកតាតាំងពាយកាលនៅពេញលេញ (រូបថត៖ CISARK)

អត្ថបទដោយ៖ ហ៊ុន ឈុនតេង



មេទ្វារមានចារឹក K.៦៤៨ ទួលអ្នកតាតាំងពាយ អំឡុងឆ្នាំ២០០៧ (រូបថត៖ CISARK)

អត្ថបទដោយ៖ ហ៊ុន ឈុនតេង



n. 715 / K. 648

សំណៅផ្តិតសិលាចារឹកទួលអ្នកតាតាំងពាយ K.៦៤៨ (រូបថត៖ CISARK)

អត្ថបទដោយ៖ ហ៊ុន ឈុនតេង